ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

26.08.24
F2288
ស.2528

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ....០៥៤.......អ.ស.ហ.ប្រក

# ប្រកាស
# ស្តីពី
# និយ័តកម្មរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ ០៦ នស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២២១ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នក/រកត/០១០៨/០៣៩ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៨ ស្ដីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នក/រកត/០៧១០/៥៩៥ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ ស្ដីពីរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ស្ដីពីការបង្កើតមូលនិធិជាតិជំនួយសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៣៤អនក្រ.បក ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ១៦០ អនក្រ.បក ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២ ស្ដីពីនិយ័តកម្មប្រព័ន្ធសន្តិសុខសង្គម
- យោងតម្រូវការចាំបាច់របស់និយ័តករសន្តិសុខសង្គមនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះ កំណត់អំពីយន្តការ វិធាន និងនីតិវិធីនៃការធ្វើនិយ័តកម្ម លើប្រតិបត្តិការរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ដើម្បីធានាបាននូវប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ដែលបច្ចុប្បន្នស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់មូលនិធិជាតិជំនួយសង្គម ដែលសរសេរជាអក្សរកាត់ថា **ម.ជ.ជ.**។

**ប្រការ៣ .-**

វាក្យសព្ទដែលប្រើក្នុងប្រកាសនេះ មាននិយមន័យដូចខាងក្រោម៖

**១-របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល** សំដៅដល់របបសន្តិសុខសង្គម ដែលគ្របដណ្តប់លើតាវកាលិក រួមមាន ការចូលនិវត្តន៍, ការបាត់បង់សម្បទាវិជ្ជាជីវៈ, មាតុភាព, គ្រោះថ្នាក់ការងារ, មរណភាព និងអ្នកក្នុងបន្ទុក ដូចមានចែងក្នុងព្រះរាជក្រឹត្យស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលបានអនុវត្តដោយ បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលសរសេរជាអក្សរកាត់ថា **ប.ជ.ស.** និងដែលធ្វើសមាហរណកម្មក្នុងដែនសមត្ថកិច្ចរបស់ **ម.ជ.ជ.**។

**២- របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន** សំដៅដល់របបសន្តិសុខសង្គម ដែលគ្របដណ្តប់ លើតាវកាលិក រួមមាន ការចូលនិវត្តន៍, ការបាត់បង់សមត្ថភាពការងារ, មាតុភាព, អាពាហ៍ពិពាហ៍គ្រាដំបូង, ពលី, មរណៈ, ពិការភាព, ជំងឺ និងគ្រួសាររបស់អតីតយុទ្ធជន ដូចមានចែងក្នុងព្រះរាជក្រឹត្យស្តីពីរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ដែលបានអនុវត្តដោយបេឡាជាតិអតីតយុទ្ធជន ដែលសរសេរជាអក្សរកាត់ថា **ប.ជ.អ.** និងដែលធ្វើសមាហរណកម្មក្នុងដែនសមត្ថកិច្ចរបស់ **ម.ជ.ជ.**។

## ជំពូកទី ២
## ស្ថាប័នមានសមត្ថកិច្ច

**ប្រការ៤ .-**

និយ័តករសន្តិសុខសង្គម ដែលសសេរជាអក្សរកាត់ថា **ន.ស.ស.** បំពេញមុខងារជាសេនាធិការឱ្យអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារដែលសរសេរជាអក្សរកាត់ថា **អ.ស.ហ.** លើការងារនិយ័តកម្ម និងត្រួតពិនិត្យរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ដូចមានចែងក្នុងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងអនុក្រឹត្យស្តីពីនិយ័តកម្មប្រព័ន្ធសន្តិសុខសង្គម។

**ប្រការ៥ .-**

**ន.ស.ស.** មានសមត្ថកិច្ចរៀបចំ និងស្នើនូវបទប្បញ្ញត្តិប្រុងប្រយ័ត្ន, ស្តង់ដាប្រតិបត្តិការ, និងវិធានចាំបាច់នានា ព្រមទាំងចាត់មន្ត្រី ធ្វើការតាមដាន និងត្រួតពិនិត្យ លើការគ្រប់គ្រង, ការចាត់ចែង និងអនុលោមភាពនៃការអនុវត្តប្រតិបត្តិការពាក់ព័ន្ធនឹងរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន។

**ន.ស.ស.** ត្រូវបង្កើតយន្តការការពារសមាជិក និងផ្សះផ្សាវិវាទក្នុងរបបសន្តិសុខសង្គមសម្រាប់

មន្ត្រីរាជការស៊ីវិល និងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន។

**ប្រការ៦ .-**

**ម.ជ.ជ.** ជាស្ថាប័នដែលមានមុខងារ និងភារកិច្ចចាត់ចែង និងគ្រប់គ្រងរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ដូចមានចែងក្នុងមាត្រា៣ និងមាត្រា៤ នៃអនុក្រឹត្យស្តីពីការបង្កើតមូលនិធិជាតិជំនួយសង្គម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែល **ន.ស.ស.** មានសមត្ថកិច្ចធ្វើនិយ័តកម្ម ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

## ជំពូកទី ៣

## តួនាទី និងភារកិច្ចរបស់ ម.ជ.ជ. ក្នុងប្រតិបត្តិការរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន

**ប្រការ៧ .-**

**ម.ជ.ជ.** ត្រូវរៀបចំ និងដាក់ជូន **ន.ស.ស.** នូវគម្រោងផែនការចំណាយប្រចាំឆ្នាំលើរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន សម្រាប់ឆ្នាំបន្ទាប់ យ៉ាងយូរត្រឹមថ្ងៃទី៣១ ខែមីនា។

**ម.ជ.ជ.** ត្រូវធ្វើបច្ចុប្បន្នភាព និងដាក់ជូន **ន.ស.ស.** នូវផែនការចំណាយប្រចាំឆ្នាំខាងលើ យ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីទទួលបានការឯកភាព និងអនុម័តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៨._**

**ម.ជ.ជ.** ត្រូវមានថ្នាលបច្ចេកវិទ្យាព័ត៌មាន ដើម្បីគ្រប់គ្រងប្រតិបត្តិការរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ប្រកបដោយប្រសិទ្ធភាព។

**ម.ជ.ជ.** ត្រូវរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងព័ត៌មាន ដោយសហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីទទួលបានដោយស្វ័យប្រវត្តិនូវទិន្នន័យ និងព័ត៌មានរបស់មន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជនដែលទទួលផលពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន។

**ប្រការ៩ .-**

**ម.ជ.ជ.** ត្រូវរៀបចំសេចក្តីណែនាំ និងទម្រង់បែបបទ ដោយរួមបញ្ចូលទាំងការកំណត់រយៈពេល ដើម្បីអនុវត្តនីតិវិធីក្នុងការទទួលតាវកាលិក ក្នុងប្រតិបត្តិការរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ។

ការចេញសេចក្តីណែនាំ និងទម្រង់បែបបទនៃការអនុវត្តនីតិវិធីខាងលើ ត្រូវដាក់ឆ្លងការពិភាក្សាជាមុនជាមួយ **ន.ស.ស.** មុននឹងដាក់ឱ្យអនុវត្ត។

**ប្រការ១០.-**

**ម.ជ.ជ.** ត្រូវរៀបចំយន្តការទទួល និងដោះស្រាយវិវាទ ឬបណ្ដឹង ដែលទាក់ទងនឹងការអនុវត្តបទប្បញ្ញត្តិនានានៃរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជនក្នុងកម្រិតប្រតិបត្តិករ។

វិវាទ ឬបណ្ដឹងនៃរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ត្រូវដោះស្រាយនៅកម្រិត **ម.ជ.ជ.**។ ក្នុងករណីមិនសះជា វិវាទ ឬបណ្ដឹងនោះអាចត្រូវបានប្ដឹងទៅ **ន.ស.ស.** មុននឹងប្ដឹងទៅតុលាការមានសមត្ថកិច្ច។

ការដោះស្រាយវិវាទ ឬបណ្ដឹងនៃរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន នៅកម្រិត **ន.ស.ស.** ត្រូវអនុវត្តតាមយន្តការ និងនីតិវិធីដែលកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

**ប្រការ១១.-**

**ម.ជ.ជ.** ត្រូវផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មាន អំពីស្ថានភាពនៃរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ដោយអនុលោមតាមគោលការណ៍ណែនាំស្ដីពីការផ្សព្វផ្សាយព័ត៌មាននៃប្រព័ន្ធសន្តិសុខសង្គម ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**ម.ជ.ជ.** ត្រូវជំរុញ និងលើកកម្ពស់ការយល់ដឹងរបស់មន្ត្រីរាជការ និងសាធារណជនលើការគ្រប់គ្រង, ការចាត់ចែង និងព័ត៌មាននៃការបើកផ្ដល់តាវកាលិក និងអត្ថប្រយោជន៍ផ្សេងៗ នៃរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រ ឬសកម្មភាពផ្សព្វផ្សាយ និងទំនាក់ទំនង។

**ប្រការ១២.-**

**ម.ជ.ជ.** ត្រូវផ្ដល់របាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ នៃប្រតិបត្តិការរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជនជូន **ន.ស.ស.**។

ប្រភេទ និងទម្រង់របាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ខាងលើ ត្រូវកំណត់ដោយសេចក្ដីណែនាំរបស់ **ន.ស.ស.**។

**ប្រការ១៣.-**

**ម.ជ.ជ.** ត្រូវផ្ដល់របាយការណ៍ និងព័ត៌មាន ដូចមានចែងក្នុងប្រកាសនេះជូន **ន.ស.ស.** ជាលាយលក្ខណ៍អក្សរ ឬតាមមធ្យោបាយផ្សេងទៀតដែលកំណត់ដោយ **ន.ស.ស.**។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ១៤ .-**

អគ្គលេខាធិការ អគ្គនាយកនៃនិយ័តករ និងប្រធានអង្គភាព ក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ មូលនិធិជាតិជំនួយសង្គម និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ចន្ទ ៧ រោច ខែ ស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ សីហា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងមុខងារសាធារណៈ
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាព និងសមាសភាពក្រុមប្រឹក្សានៃ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- ដូចប្រការ១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ